# បទបង្ហាញ

# ស្ដីពី

# វិធានការគ្រប់គ្រងវត្តមានជនបរទេស

# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

# មាតិកា


I. តួនាទី ភារកិច្ចស្នូលសំខាន់ៗ

II. ស្ថានភាពជនបរទេស

III. វិធានការគ្រប់គ្រងវត្តមានជនបរទេស

IV. សន្និដ្ឋាន

V. បញ្ហាប្រឈម

VI. ដំណោះស្រាយ និងសំណូមពរ

# I.តួនាទី ភារកិច្ចស្នូលសំខាន់ៗ

ក្នុងនាមជាសេនាធិការផ្ទួនក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានតួនាទី ភារកិច្ចស្នូលសំខាន់ៗ៖

- គ្រប់គ្រងការចេញ ចូល ប្រទេសនៅតាមច្រកទ្វារអន្តរជាតិ
- គ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ស្រាវជ្រាវស៊ើបអង្កេតស្វែងរកជនបរទេសស្នាក់នៅនិងធ្វើការខុសច្បាប់  មុខសញ្ញាឧក្រិដ្ឋជនលួចចូលមកសម្ងំលាក់ខ្លួន  និងជនពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

# II.ស្ថានភាពជនបរទេស

- កំណើនជនបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងការគ្រប់គ្រងវត្តមានជនបរទេសឲ្យមានប្រសិទ្ធភាព
- ធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ





# III. វិធានការគ្រប់គ្រងជនបរទេស

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- មាត្រា ១៨ នៃច្បាប់អន្តោប្រវេសន៍ "ម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ត្រូវជូនដំណឹងក្នុងរយៈពេល២៤ ម៉ោងដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាននៃជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលបានមកស្នាក់នៅ"។

ច្បាប់
ស្ដីពី
អន្តោប្រវេសន៍


ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១

ភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្ដីទី

ជា ស៊ីម

មាត្រា ១៨ .-

ម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ត្រូវជូនដំណឹងក្នុងរយៈពេល ២៤ ម៉ោង ដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាននៃជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលបានមកស្នាក់នៅ ។

មាត្រា ២២ .-

ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវត្រួតពិនិត្យជនបរទេសទាំងអស់ ដែលបានតាំងទីលំនៅ ឬទើបនឹងមកតាំងទីលំនៅក្នុងដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន ។

# III. វិធានការគ្រប់គ្រងជនបរទេស

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (ត)

- អនុក្រឹត្យ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន្តចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា


ព្រះរាជាណាចក្រកម្ពុជា
រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ
លេខ: ១២៣ អនក្រ.បក
អនុក្រឹត្យ
ស្តីពី
បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែន
អន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា


មាត្រា៣១.-
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ខែ មិថុនា ឆ្នាំ២០១៦
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
សម្តេចក្រឡាហោម ស ខេង

# III. វិធានការគ្រប់គ្រងជនបរទេស

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (ត)

- អនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :០៣ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ**

**មាត្រា២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**មាត្រា១៤.-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ មុននឹងអនុញ្ញាតឱ្យជនបរទេសស្នាក់នៅក្នុងទីតាំងស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ត្រូវឱ្យជនបរទេសផ្តល់ឯកសារបញ្ជាក់អំពីសិទ្ធិស្នាក់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ មិនត្រូវអនុញ្ញាតឱ្យជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនឡើយ។

**មាត្រា២០.-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលមានចេតនាលាក់បាំង និងអនុញ្ញាតឱ្យជនបរទេសដែលចូលមកព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ត្រូវផាកពិន័យជាប្រាក់ចំនួន៤ ០០០ ០០០(បួនលាន)រៀល សម្រាប់ជនបរទេសម្នាក់ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលបានកំណត់ក្នុងច្បាប់ជាធរមានឡើយ។

**មាត្រា២១.-**

អាជ្ញាធរមានសមត្ថកិច្ចដែលមិនបានបំពេញតួនាទីរបស់ខ្លួនដោយភាពស្មោះត្រង់ មានចេតនាលាក់បាំងជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ឱ្យស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំណាមួយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវទទួលរងទណ្ឌកម្មវិន័យបណ្តេញចេញពីក្របខ័ណ្ឌការងារ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលបានកំណត់ក្នុងច្បាប់ជាធរមានឡើយ។

# III. វិធានការគ្រប់គ្រងជនបរទេស

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (ត)

- សេចក្តីណែនាំលេខ០២៨ ស.ណ.ន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ស្តីពី ការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០២៨ ស.ណ.ន

សេចក្តីណែនាំ
ស្តីពី
ការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា



ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ ត្រូវផ្សព្វផ្សាយ និងចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។/.

ថ្ងៃ សុក្រ ៣កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- អគ្គនាយកដ្ឋានរដ្ឋបាល
- សាលារាជធានី-ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# III. វិធានការគ្រប់គ្រងជនបរទេស

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (ត)

- ប្រកាសអន្តរក្រសួងលេខ១៧៥០ ប្រក ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីអន្តោប្រវេសន៍



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
លេខ : ១៧៥០ ប្រក.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអន្តរក្រសួង
ស្តីពី
ការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីអន្តោប្រវេសន៍

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ប្រការ១០ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គស្នងការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៧ ៩ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# III. វិធានការគ្រប់គ្រងជនបរទេស

## ខ.វិធានការ និងយន្តការគ្រប់គ្រង

- ផែនការអនុវត្តលេខ០០៤ ផ.ក /អអ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអន្តោប្រវេសន៍
លេខ: ០០៤ ផ.ក/អអ

ផែនការអនុវត្ត
សេចក្តីណែនាំលេខ០២៨ ស.ណ.ន ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០១៩ របស់
ក្រសួងមហាផ្ទៃ
ស្តីពី ការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា



ផែនការនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៩
អគ្គនាយកអន្តោប្រវេសន៍

នាយឧត្តមសេនីយ៍.គៀត_ចន្ទថារិទ្ធ

ចម្លងជូន:
-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
"ដើម្បីគោរពជូនជ្រាប"
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
-អគ្គនាយកដ្ឋានរដ្ឋបាល
-សាលារាជធានី-ខេត្ត
"ដើម្បីសហការ"
-ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអន្តោប្រវេសន៍
-នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍
-ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# III. វិធានការគ្រប់គ្រងជនបរទេស

## ខ.វិធានការ និងយន្តការគ្រប់គ្រង (ត)

- ផែនការអនុវត្តលេខ០០៣ ផក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះត្រួតពិនិត្យវត្តមានស្នាក់នៅរបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០០៣ ផក

ផែនការអនុវត្ត
ស្តីពី
ការចុះត្រួតពិនិត្យវត្តមានស្នាក់នៅរបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា



ផែនការនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

អតិសន្តិបណ្ឌិត ស សុខា

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតី នាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងទេសចរណ៍
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីជូនជ្រាប"

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# III. វិធានការគ្រប់គ្រងជនបរទេស

## ខ.វិធានការ និងយន្តការគ្រប់គ្រង (ត)

- សេចក្តីសម្រេចលេខ៥៣២៣ សសរ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការចាត់តាំងគណៈបញ្ជាការដឹកនាំរួម ដើម្បីអនុវត្តផែនការលេខ០០៣ ផក របស់ក្រសួងមហាផ្ទៃ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៥៣២៣ សសរ

សេចក្តីសម្រេច
ស្តីពី
ការចាត់តាំងគណៈបញ្ជាការដឹកនាំរួម ដើម្បីអនុវត្ត
ផែនការលេខ ០០៣ ផក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ
ស្តីពីការចុះត្រួតពិនិត្យវត្តមានស្នាក់នៅរបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា



**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ... ខែ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០២៤
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

-៥-

# III. វិធានការគ្រប់គ្រងជនបរទេស

## គ.ប្រព័ន្ធគ្រប់គ្រងអន្តោប្រវេសន៍



# III. វិធានការគ្រប់គ្រងជនបរទេស

## ប្រព័ន្ធគ្រប់គ្រងព្រំដែនកម្ពុជា

TMS / Smart Gate / BLTMS









# III. វិធានការគ្រប់គ្រងជនបរទេស

## វីដេអូអំពីការប្រើប្រាស់ប្រព័ន្ធអន្តោប្រវេសន៍នៅអាកាសយានដ្ឋានអន្តោរជាតិតេជោ



# III. វិធានការគ្រប់គ្រងជនបរទេស

## ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS)

- ផ្តល់ភាពងាយស្រួលដល់ម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅដ្ឋានគ្រប់ប្រភេទក្នុងការរាយការណ៍វត្តមានជនបរទេសដែលមកស្នាក់នៅក្នុងទីតាំងរបស់ខ្លួនដល់មន្ត្រីនគរបាលមានសមត្ថកិច្ចដូចបានកំណត់ក្នុងមាត្រា១៨ នៃច្បាប់ស្តីពីអន្តោប្រវេសន៍
- ផ្តល់គណនីជូនមន្ត្រីនគរបាលមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងវត្តមានជនបរទេសក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន
- អត្ថប្រយោជន៍របស់ប្រព័ន្ធ FPCS៖
  - **សម្រាប់ម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅឋាន៖**
    - អាចរាយការណ៍ពីវត្តមានជនបរទេសតាមប្រព័ន្ធឌីជីថលដែលអាចទាញយកកម្មវិធីតាមទូរស័ព្ទដៃ (Mobile App) ឬតាមរយៈគេហទំព័រ (Website)
    - ការចុះវត្តមានជនបរទេសចូលប្រព័ន្ធធ្វើឡើងដោយការស្កេនទាញយកទិន្នន័យមានភាពលឿនរហ័ស និងសុក្រិត្យភាព
    - ងាយស្រួលក្នុងការគ្រប់គ្រងវត្តមានជនបរទេសដែលកំពុងស្នាក់នៅទីតាំងរបស់ខ្លួន។

# III. វិធានការគ្រប់គ្រងជនបរទេស

## ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS)

- អត្ថប្រយោជន៍របស់ប្រព័ន្ធ FPCS៖
  - **សម្រាប់មន្ត្រីមានសមត្ថកិច្ច៖**
    - អាចគ្រប់គ្រង និងដឹងទីតាំងដែលមានជនបរទេសស្នាក់នៅក្នុងមូលដ្ឋាន
    - អាចគ្រប់គ្រងទិន្នន័យជនបរទេសដែលកំពុងស្នាក់អាស្រ័យ(ចូល-ចេញ) នៅក្នុងមូលដ្ឋាន
    - បំរើឲ្យការងារគ្រប់គ្រងសន្តិសុខ ស្រាវជ្រាវ រកជនបរទេស ឬមុខសញ្ញាជនបរទេស
    - ចាត់វិធានការការពារសន្តិសុខ សុវត្ថិភាព ភ្ញៀវបរទេសដែលមកស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួនបានទាន់ពេលវេលា
    - អាចទាញយករបាយការណ៍បានច្រើនទម្រង់ និងងាយស្រួលក្នុងការរាយការណ៍ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។

## III. វិធានការគ្រប់គ្រងជនបរទេស

### ប្រព័ន្ធបន្តការស្នាក់នៅបណ្តោះអាសន្ន

- សម្រាប់បន្តការស្នាក់នៅបណ្តោះអាសន្ន
- លក្ខខណ្ឌតម្រូវ៖
  - មានឈ្មោះក្នុងប្រព័ន្ធ FPCS
  - មានបណ្ណការងារ
  - មានលិខិតបញ្ជាក់បុគ្គលិកក្រុមហ៊ុន (ហត្ថពលករបរទេស)
  - មានបណ្ណប៉ាតង់ ឬលិខិតបញ្ជាក់អាជីវកម្ម (និយោជក ឬម្ចាស់អាជីវកម្ម)

# IV. សន្និដ្ឋាន

- អាស្រ័យដោយមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត ការដាក់ចេញនូវវិធានការ និងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គាំទ្រការងារជំនាញធ្វើឲ្យការផ្តល់សេវា និងការគ្រប់គ្រងជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពងាយស្រួលប្រកបដោយប្រសិទ្ធភាព
- ទោះបីមានប្រព័ន្ធ FPCS សម្រាប់រាយការណ៍វត្តមានស្នាក់នៅរបស់ជនបរទេស ប៉ុន្តែតាមទិន្នន័យបង្ហាញថាចំនួនជនបរទេសដែលបានរាយការណ៍ក្នុងប្រព័ន្ធមិនសមមាត្រនឹងចំនួនជនបរទេសចូលព្រះរាជាណាចក្រកម្ពុជា។

## V. បញ្ហាប្រឈម

- ម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅឋានមួយចំនួនពុំទាន់បានបង្កើតគណនីប្រព័ន្ធ FPCS។ មួយចំនួនទៀតបានបង្កើតប៉ុន្តែមិនបានរាយការណ៍ ឬពុំទាន់យល់អំពីការប្រើប្រាស់ប្រព័ន្ធនេះនៅឡើយ។
- នគរបាលមានសមត្ថកិច្ចនៅមូលដ្ឋានមួយចំនួនពុំទាន់បានធ្វើការផ្សព្វផ្សាយឱ្យទូលំទូលាយដល់ម្ចាស់ឬអ្នកគ្រប់គ្រងលំនៅឋានដែលមានជនបរទេសស្នាក់នៅអំពីកាតព្វកិច្ចក្នុងការរាយការណ៍វត្តមានជនបរទេសជូននគរបាលមានសមត្ថកិច្ចស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។
- មានទីតាំងមួយចំនួនសមត្ថកិច្ចនៅមូលដ្ឋានពុំអាចចូលត្រួតពិនិត្យបាន ជាពិសេសនៅតាមសណ្ឋាគារធំៗ ទីតាំងកាស៊ីណូ កសិដ្ឋានធំៗ...។

## V. បញ្ហាប្រឈម

- សមត្ថកិច្ចនៅតាមមូលដ្ឋានមួយចំនួនពុំសូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងវត្តមានជនបរទេសនៅក្នុងភូមិសាស្រ្តទទួលខុសត្រូវរបស់ខ្លួនដែលច្បាប់ស្តីពីអន្តោប្រវេសន៍ បានប្រគល់សមត្ថកិច្ចជូន ដោយពួកគាត់យល់ថាកិច្ចការនេះជាសមត្ថកិច្ចផ្ទាល់របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (មាត្រា២២ បានចែងថា៖ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលខុសត្រូវត្រួតពិនិត្យជនបរទេសទាំងអស់ដែលមកតាំងទីលំនៅ ឬទើបមកតាំងទីលំនៅក្នុងដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន)។

# VI. ដំណោះស្រាយ និងសំណូមពរ

- ស្នើជំរុញការអនុវត្តផែនការលេខ ០០៣ ផក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីការចុះត្រួតពិនិត្យវត្តមានស្នាក់នៅរបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។
- ស្នើអាជ្ញាធរមានសមត្ថកិច្ច ពិសេសស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ពង្រឹងការគ្រប់គ្រងវត្តមានជនបរទេសក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវផ្សព្វផ្សាយ ណែនាំ និងតាមដានត្រួតពិនិត្យម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅឋាន និងទីតាំងដែលមានជនបរទេសស្នាក់នៅឱ្យរាយការណ៍ពីវត្តមានជនបរទេសចូលក្នុងប្រព័ន្ធ FPCS ឱ្យបានគ្រប់ៗគ្នា និងគ្រប់ទីតាំង។
- ស្នើចាត់វិធានការតាមផ្លូវច្បាប់ឲ្យបានម៉ឺងម៉ាត់ចំពោះបុគ្គលល្មើសនឹងច្បាប់ស្ដីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

# VI. ដំណោះស្រាយ និងសំណូមពរ

- ស្នើអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារព្រំដែនទាំងអស់ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតក្នុងការបង្ការ ទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់នៃជនបរទេសមកក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយហេតុថា អត្រានៃការលួចជ្រៀតចូលកម្ពុជាដោយខុសច្បាប់នៅក្នុងឆ្នាំ២០២៥កន្លងមកនេះនៅមានចំនួនច្រើននៅឡើយ។
- ស្នើសុំរៀបចំក្រុមការងារដើម្បីសិក្សា និងអភិវឌ្ឍន៍ប្រព័ន្ធ FPCS ដែលមានស្រាប់ទៅជាប្រព័ន្ធគ្រប់គ្រងការស្នាក់នៅបណ្ដោះអាសន្ន នៅតាមទីតាំងប្រមូលផ្ដុំ ដូចមានចែងក្នុងអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ និងរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីដាក់ឲ្យប្រើប្រាស់ប្រព័ន្ធនេះ។

# សូមថ្លែងអំណរគុណ
# ចំពោះការយកចិត្តទុកដាក់ស្តាប់



# Scan ទីនេះដើម្បីទាញយកឯកសារ

Scan me!